**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# សុន្ទរកថាស្វាគមន៍


**របស់បណ្ឌិត អូន ព័ន្ធមុនីរ័ត្ន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**និងជាប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**


**ថ្លែងក្នុង**

**«កិច្ចប្រជុំត្រួតពិនិត្យប្រចាំឆ្នាំនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ»**

**រាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១៥**

- **ខ្ញុំបាទសូមគោរពសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា,**
- **ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី, ភ្ញៀវជាតិ និងអន្តរជាតិទាំងអស់ ជាទីមេត្រី!**

ថ្ងៃនេះ គឺជាទិវាដ៏មហានក្ខត្តឫក្ស និងប្រកបដោយកិត្តយសខ្ពង់ខ្ពស់ក្រៃលែង ដែលយើងបានមកជួបជុំគ្នាដើម្បីធ្វើការត្រួតពិនិត្យប្រចាំឆ្នាំ ២០១៤ នៃការអនុវត្ត **«កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ-ដំណាក់កាលទី ២»** ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុត របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។** ក្នុងឋានៈជាប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, ខ្ញុំសូមគោរពស្វាគមន៍ និងថ្លែងអំណរគុណដជ្រាលជ្រៅបំផុត ចំពោះ **សម្តេចតេជោនាយក-រដ្ឋមន្ត្រី** ព្រមទាំងឯកឧត្តម, លោកជំទាវ, លោក, លោកស្រី, ភ្ញៀវជាតិ និងអន្តរជាតិទាំងអស់ ដែលបានចំណាយពេលវេលាដ៏មានតម្លៃ មកចូលរួមជាអធិបតិ និងជាកិតយស ក្នុងកិច្ចប្រជុំនេះ។

«**ដំណាក់កាលទី ១ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**» ត្រូវបានប្រកាសដាក់ឱ្យអនុវត្តដោយរាជរដ្ឋាភិបាលនៅចុងឆ្នាំ ២០០៤។ ពេលនោះ គោលដៅចម្បងរបស់យើងគឺ **«ការបង្កើនភាព-ជឿទុកចិត្តលើថវិកា»** ដែលផ្តោតលើការពង្រឹងការប្រមូល និងការគ្រប់គ្រងចំណូល, ការពង្រឹងការគ្រប់គ្រង

សាច់ប្រាក់ និងការកែលម្អនីតិវិធីនៃការអនុវត្តថវិកា។ ស្របតាមគោលដៅនេះ, នៅក្នុងដំណាក់កាលទី ១, យើងបានដាក់ចេញ និងជំរុញអនុវត្តវិធានការជាច្រើន ដែលសំដៅជាសំខាន់លើការដោះស្រាយបញ្ហាបំណុលសាច់ប្រាក់ និងកង្វះសាច់ប្រាក់ដ៏រ៉ាំរ៉ៃ។ បន្ទាប់ពីបានអនុវត្តអស់រយៈពេល ៤ ឆ្នាំ និងដោយពិនិត្យឃើញថា ភាពជឿទុកចិត្តនៃថវិកា ត្រូវបានសម្រេចជាមូលដ្ឋាន, យើងក៏បានដាក់ឱ្យអនុវត្តនូវ «**ដំណាក់កាលទី ២ នៃកម្មវិធីកែទម្រង់ការ-គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**» នៅចុងឆ្នាំ ២០០៨ ជាមួយនឹងគោលដៅចម្បងនៃ **«ការបង្កើនគណនេយ្យភាពហិរញ្ញវត្ថុ»** ដោយផ្ដោតជាសំខាន់ទៅលើការរៀបចំ, កែលម្អ និងពង្រឹងការកត់ត្រា និងការធ្វើរបាយការណ៍គណ-នេយ្យ និងហិរញ្ញវត្ថុ ឱ្យកាន់តែត្រឹមត្រូវ, ច្បាស់លាស, សុក្រឹត និងទាន់ពេលវេលា, ស្របតាមស្តង់ដារអន្តរជាតិ។ យើងបានចាយពេលជាង ៦ ឆ្នាំ ក្នុងការត្រៀមរៀបចំសមាសភាគជាច្រើនសម្រាប់កសាង **«មូលដ្ឋានគ្រឹះនៃប្រព័ន្ធថវិកាថ្មី»** ដែលជា **«ស្នូលនៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈទាំងមូល»**។

ស្ថិតនៅចុងដំណាក់កាលទី ២ នាពេលនេះ, ការកែទម្រង់របស់យើងបានឈានមកដល់ចំណុចរបត់មួយដ៏សំខាន់ នោះគឺដំណាក់កាលនៃការចាប់ផ្តើមធ្វើការផ្លាស់ប្តូរមួយចំណែកម្តងៗទៅលើប្រព័ន្ធថវិកាបច្ចុប្បន្ន ដោយចាប់ផ្តើមពីចុងឆ្នាំ ២០១៥ នេះទៅ តាមរយៈការដាក់ឱ្យអនុវត្តមាតិកាថវិកាថ្មី, ស្តង់ដារគណនេយ្យ និងប្លង់គណ-នេយ្យថ្មី, អង្គភាពថវិកា និងនីតិវិធីអនុវត្តថវិកាថ្មី, រួមជាមួយនឹងប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់កិច្ចប្រតិបត្តិការអនុវត្តថវិកាជំហានទី ១, ព្រមទាំងការចាប់ផ្តើមពង្រាង និងពង្រីកការអនុវត្តថវិកាកម្មវិធីពេញលេញ, ជាជំហានៗ, នៅក្នុងចំណោមក្រសួង- ស្ថាប័នរដ្ឋគ្រប់ថ្នាក់, ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ, ដោយចាប់ផ្តើមពីឆ្នាំ ២០១៥ នេះទៅរហូតដល់ឆ្នាំ ២០១៨ ស្របតាមឯកសារ «**ទស្សនាទានស្តីពីទិសដៅយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកា ២០១៣-២០២០**» ក្នុងគោលដៅជាជំហានៗឆ្ពោះទៅកែប្រែប្រព័ន្ធថវិកាបច្ចុប្បន្នទាំងស្រុងពី **«ប្រព័ន្ធថវិកាផ្តោតលើធាតុចូល និងមជ្ឈការ ទៅជាប្រព័ន្ធថវិកាផ្តោតលើលទ្ធផល ឬធាតុចេញ និងវិមជ្ឈការ»** ឱ្យបាន នៅឆ្នាំ ២០២០។ ការរៀបចំការផ្លាស់ប្តូរនេះ គឺជាការងារស្នូលនៃ «**ដំណាក់កាលទី ៣ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**» របស់យើង ដែលកំណត់យក **«ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ»** ជា**គោលដៅចម្បង**។ បន្ទាប់មកទៀត, តាមការគ្រោងទុក, ចាប់ពីឆ្នាំ ២០២០ ទៅ យើងនឹងបន្តពង្រឹង និងពង្រីកការអនុវត្តប្រព័ន្ធថវិកាកម្មវិធីដែលផ្តោតលើលទ្ធផល ឬធាតុចេញនេះ, ជាបណ្តើរៗ, ឆ្ពោះទៅរក **«ការបង្កើនគណនេយ្យភាពសមិទ្ធកម្ម»** នៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកម្ពុជាទាំងមូល ឱ្យបានសម្រេចនៅឆ្នាំ ២០២៥ ដែលនេះគឺជាគោលដៅចម្បងនៃដំណាក់កាលចុងក្រោយ គឺ «**ដំណាក់កាលទី ៤ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**»។

- **សម្តេចតេជោនាយករដ្ឋមន្ត្រី ជាទីគោរពដ៏ខ្ពង់ខ្ពស់,**
- **ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី, ភ្ញៀវជាតិ និងអន្តរជាតិ ជាទីមេត្រី!**

ពិតណាស់ថា គោលដៅរបស់យើងអាចមានមហិច្ឆតាបន្តិច, ប៉ុន្តែបើយើងពិនិត្យទៅលើសមិទ្ធផលដែលសម្រេចបានគួរជាទីលើកទឹកចិត្ត និងបទពិសោធន៍ដែលទទួលបានកន្លងមក ព្រមទាំងទទួលស្គាល់នូវភាពចាំបាច់

និងភាពបន្ទាន់នៃកិច្ចការកែទម្រង់នោះ, យើងច្បាស់ជាមិនត្រឹមតែទទួលស្គាល់ថា គោលដៅប្រកបដោយមហិច្ឆិតានេះ គឺពិតជាអ្វីដែលយើងត្រូវតែធ្វើឱ្យសម្រេចបានប៉ុណ្ណោះទេ តែថែមទាំងមានតណ្ហាចង់ជំនះធ្វើឱ្យបានកាន់តែលឿនថែមទៀត។ ដូចខ្ញុំបានគូសបញ្ជាក់ពីខាងលើថា ពេលនេះ ការកែទម្រង់របស់យើងបានឈានមកដល់ចំណុចរបត់មួយដ៏សំខាន់បំផុត ហើយឆ្នាំ ២០១៤ និង ២០១៥ គឺជាដំណាក់កាលអន្តរកាលនៃការកសាងមូលដ្ឋានគ្រឹះសម្រាប់ការផ្លាស់ប្តូរនៅក្នុងប្រព័ន្ធថវិកា។ ដូច្នេះ ក្នុងនាម **គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ** ខ្ញុំសូមការអនុញ្ញាតរាយការណ៍ជូនអង្គពិធីទាំងមូលជ្រាបអំពីសមិទ្ធផលសំខាន់ៗជាគន្លឹះ ដែលយើងសម្រេចបាននៅក្នុងការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ទាំងក្នុងដំណាក់កាលទី ១ កន្លងទៅ និងក្នុងដំណាក់កាលទី ២ ដែលកំពុងតែឈានទៅបញ្ចប់នៅចុងឆ្នាំ ២០១៥ នេះ ព្រមទាំងការត្រៀមលក្ខណៈចាប់ផ្តើមដំណាក់កាលទី ៣ នៅឆ្នាំ ២០១៦ ខាងមុខដូចខាងក្រោម៖

**ទីមួយ**: ជាការពិត ដូចខ្ញុំបានគូសបញ្ជាក់ខាងលើថា យើងបានចាប់ផ្តើមដំណាក់កាលទី ១ នៃការកែទម្រង់ដោយផ្តោតជាសំខាន់ទៅលើការដោះស្រាយបញ្ហាបំណុលសាច់ប្រាក់ និងកង្វះសាច់ប្រាក់ដ៏រ៉ាំរ៉ៃ ដែលជាបញ្ហាប្រឈមខ្លាំងរបស់យើងនាពេលនោះ។ យ៉ាងណាមិញ គោលដៅចម្បងរបស់យើង គឺការបង្កើន និងរក្សាភាពជឿទុកចិត្តលើថវិកាប្រកបដោយចរភាព, ទាំងនៅក្នុងការអនុវត្តក្នុងឆ្នាំ, ទាំងសម្រាប់រយៈពេលមធ្យម, នោះគឺការធានាលំហូរចំណូល និងចំណាយ ប្រកបដោយភាពរលូន និងមានស្ថិរភាព ព្រមទាំងធានាការគ្រប់គ្រងបំណុលត្រូវសង និងបំណុលត្រូវទារ ប្រកបដោយប្រសិទ្ធភាព។ ផ្អែកលើលទ្ធផលសម្រេចបាន, យើងអាចសន្និដ្ឋានបានថា យើងសម្រេចបានជាមូលដ្ឋានហើយ នូវ **«ភាពជឿទុកលើថវិកា»** នេះ នោះគឺការជំរុញ និងការចាត់វិធានការគ្រប់បែបយ៉ាង ដើម្បីប្រមូលចំណូល និងអនុវត្តចំណាយឱ្យបានតាមច្បាប់កំណត់ ព្រមទាំងទូទាត់ថវិកាឱ្យបានទាន់ពេលវេលាក្នុងឆ្នាំ។ ក៏ប៉ុន្តែ កិច្ចការនេះមិនទាន់ចប់ត្រឹមនេះទេ! យើងកំពុងតែបន្តពង្រឹងការព្យាករណ៍ និងការគណនាតម្រូវការចំណាយ ក៏ដូចជាការរៀបចំ និងអនុវត្តកម្មវិធីចំណូល-ចំណាយប្រចាំត្រីមាស ឱ្យបានកាន់តែសុក្រឹត ដើម្បីឈានទៅធានារក្សាភាពជឿទុកចិត្តលើថវិកាប្រកបដោយចីរភាព។ តាមការរំពឹងទុក, ការងារនេះគ្រោងនឹងបញ្ចប់នៅចុងឆ្នាំ ២០១៥ នេះ, ក៏ប៉ុន្តែ ស្របតាមស្ថានភាពជាក់ស្តែង និងអាស្រ័យដោយលទ្ធផលនៃកិច្ចពិភាក្សានៅក្នុងកិច្ចប្រជុំប្រចាំឆ្នាំ រយៈពេល ២ ថ្ងៃនេះ, ការងារនេះអាចនឹងត្រូវបន្តទៅក្នុងដំណាក់កាលទី ៣ ទៀត។

**ទីពីរ**: ដូចខ្ញុំបានគូសបញ្ជាក់ខាងលើដែរថា ដំណាក់កាលទី ២ ត្រូវបានចាប់ផ្តើមនៅចុងឆ្នាំ ២០០៨ ដោយផ្តោតជាសំខាន់ទៅលើការបង្កើនស័ក្តិសិទ្ធភាព និងប្រសិទ្ធភាពនៃកិច្ចប្រតិបត្តិការគណនេយ្យ និងហិរញ្ញវត្ថុសាធារណៈ ពោលគឺ ការបង្កើនភាពត្រឹមត្រូវ, ច្បាស់លាស់, សុក្រឹតភាព និងភាពទាន់ពេលវេលា ក្នុងការកត់ត្រា និងការធ្វើរបាយការណ៍គណនេយ្យ និងហិរញ្ញវត្ថុ ឱ្យស្របទៅនឹងស្តង់ដារអន្តរជាតិ តាមរយៈការដាក់ឱ្យអនុវត្តមាតិកាថវិកាថ្មី, ប្លង់គណនេយ្យថ, អង្គភាពថវិកា និងនីតិវិធីអនុវត្តថវិកាថ្មី ព្រមទាំងប្រព័ន្ធពតិមានវិទ្យាសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុ ដែលជំហានទី ១ នៃប្រព័ន្ធនេះ នឹងត្រូវបានដាក់ឱ្យអនុវត្តនៅក្នុងខែ កក្កដា ខាងមុខ។ តាមគោលដៅគ្រោងទុក, សមាសភាគសំខាន់ៗជាមូលដ្ឋាន រួមទាំងហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាព័ត៌មានជំហានទី ១

សម្រាប់គាំទ្រដល់កចប្រតិបត្តិការនៃប្រព័ន្ធថវិការថ្មី នឹងត្រូវសម្រេចឱ្យបាននៅចុងឆ្នាំ ២០១៥ នេះ។ ច្បាស់ណាស់ថា ការងារនេះ នឹងត្រូវបានបន្តពង្រឹង និងពង្រីកជាបណ្តើរៗទៅមុខទៀត, ទាំងក្នុងទិដ្ឋភាពនៃការបង្កើនភាពគ្រប់ជ្រុងជ្រោយនៃប្រព័ន្ធ, ទាំងក្នុងទិដ្ឋភាពនៃការពង្រីកវិសាលភាពនៃការអនុវត្តទៅតាមក្រសួង-ស្ថាប័នរដ្ឋ, ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ នេះ ក៏ជាប្រធានបទដ៏សំខាន់មួយដែរ សម្រាប់ការពិភាក្សានៅក្នុងកិចប្រជុំត្រួតពិនិត្យប្រចាំឆ្នាំរយៈពេល ២ ថ្ងៃនេះ ដើម្បីពិនិត្យវាយតម្លៃទៅលើវឌ្ឍនភាព និងបញ្ហាប្រឈមនានា ក្នុងទិសដៅរៀបចំផែនការសកម្មភាព និងកំណត់គោលដៅសម្រាប់ជំហានបន្ទាប់ នៅក្នុងក្របខ័ណ្ឌនៃការរៀបចំផែនការសកម្មភាពរួមសម្រាប់ដំណាក់កាលទី ៣។

**ទីបី**: នៅក្នុងក្របខ័ណ្ឌនៃអភិក្រមជាជំហានៗ និងជាដំណាក់កាលៗរបស់យើង, ទោះជាការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ គឺជាគោលដៅចម្បងនៃដំណាក់កាលទី ៣ ក៏ពិតមែន, ប៉ុន្តែ យើងក៏បានចាប់ផ្តើមរៀបចំក្របខ័ណ្ឌ និងដាក់ឱ្យអនុវត្តសាកល្បងការងារនេះ, ជាបណ្តើរៗ, តាំងពីដំណាក់កាលទី ២ មកម៉េះ។ ជាក់ស្តែង ផែនការយុទ្ធសាស្ត្រថវិកា ដែលកំណត់ឱ្យគ្រប់ក្រសួង-ស្ថាប័ន ត្រូវរៀបចំគោលបំណងគោលនយោបាយ និងកម្មវិធី ឬយុទ្ធសាស្ត្រអាទិភាព សម្រាប់ជាមូលដ្ឋាននៃការរៀបចំថវិកាប្រចាំឆ្នាំនោះ ត្រូវបានដាក់ឱ្យអនុវត្តតាំងពីឆ្នាំ ២០០៨ ហើយថវិកាកម្មវិធីក៏ត្រូវបានដាក់ឱ្យអនុវត្តសាកល្បងតាមផ្នែកមួយចំនួន នៅក្នុងក្រសួងចំនួន ៨ តាំងពីឆ្នាំ ២០០៨ មកដែរ។ ម៉្យាងទៀត នៅក្នុងក្របខ័ណ្ឌនៃការដាក់ឱ្យអនុវត្តថវិកាកម្មវិធីពេញលេញនៅក្នុងក្រសួងចំនួន ១០ ក្នុងឆ្នាំ ២០១៥ នេះ ក៏មានរួមបពាលនូវការដាក់ឱ្យដំណើរការ **«អង្គភាពថវិកា»** ផងដែរ។ លើសពីនេះ រាជរដ្ឋាភិបាលកបានសម្រេចរួចហើយដែរ ឱ្យរៀបចំដាក់ក្រសួង-ស្ថាប័នចំនួន ១៥ និងរដ្ឋបាលរាជធានី-ខេត្តមួយចំនួនទៀត ទៅក្នុងផែនការពង្រីកការអនុវត្តថវិកាកម្មវិធីនៅឆ្នាំ ២០១៦។ ផែនការពង្រីកការអនុវត្តថវិកាកម្មវិធីនេះ នឹងត្រូវបានជំរុញជាបន្តបន្ទាប់ទៀត, ដែលតាមការគ្រោងទុក, រហូតដល់ឆ្នាំ ២០១៨ ក្រសួង-ស្ថាប័នរដ្ឋទាំងអស់ នឹងត្រូវអនុវត្តថវិកាកម្មវិធី ហើយពេលនោះយើងនឹងត្រូវរៀបចំក្របខ័ណ្ឌនៃប្រព័ន្ធថ្មីទាំងស្រុង, ទាំងយន្តការថ្មី, ទាំងក្របខ័ណ្ឌគតិយុត្តថ្មី, សម្រាប់ការអនុវត្តប្រព័ន្ធថវិកាថ្មី នៅឆ្នាំ ២០២០ នោះគឺប្រព័ន្ធថវិកាផ្តោតលើលទ្ធផល ឬធាតុចេញ និងវិមជ្ឈការ ស្របតាម «**ទស្សនាទានស្តីពីការកែទម្រង់ប្រព័ន្ធថវិកាកម្ពុជា ២០១៣-២០២០**» របស់រាជរដ្ឋាភិបាល។ ដូច្នេះ តាមរយៈអភិក្រមនៃការអនុវត្តនេះ, ការកែទម្រង់របស់យើងនឹងមានលក្ខណៈកាន់តែស៊ីជម្រៅ និងមានវិសាលភាពកាន់តែធំទៅៗ, ចាប់ពីឆ្នាំ ២០១៦ តទៅ, នៅពេលដែលដំណាក់កាលទី ៣ ត្រូវបានចាប់ផ្តើម។ ផែនការសកម្មភាពរួមសម្រាប់អនុវត្តកិចការនេះ នឹងត្រូវបានពិភាក្សាជាប្រធានបទគន្លឹះមួយ នៅក្នុងកិចប្រជុំត្រួតពិនិត្យប្រចាំឆ្នាំរបស់យើងនេះ។

**ទីបួន**: ក្នុងការត្រៀមលក្ខណៈសម្រាប់ការផ្លាស់ប្តូរពីដំណាក់កាលទី ២ ទៅដំណាក់កាលទី ៣, **គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ** បានធ្វើការត្រួតពិនិត្យ និងវាយតម្លៃទៅលើការអនុវត្តដំណាក់កាលទី ២ ទាំងមូល នៅឆ្នាំ ២០១៣ ហើយបានរៀបចំផែនការសកម្មភាពសម្រាប់ដំណាក់កាលអន្តរកាល សម្រាប់ឆ្នាំ ២០១៤-២០១៥ (CAP2-New) ព្រមទាំងបាន និងកំពុងប្រើប្រាស់ក្របខ័ណ្ឌគណនេយ្យភាព

ហិរញ្ញវត្ថុនៃចំណាយសាធារណៈ (Public Expenditure and Financial Accountability-PEFA- Framework) ដែលជាក្របខ័ណ្ឌស្តង់ដារអន្តរជាតិ ដើម្បីធ្វើការវាយតម្លៃទៅលើប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកម្ពុជាទាំងមូល។ ផ្អែកលើលទ្ធផលនៃការវាយតម្លៃទាំងនេះ រួមជាមួយនឹងសមិទ្ធផលសម្រេចបាន និងបទពិសោធន៍ទទួលបានកន្លងមក, **គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ** បានរៀបចំ ***ក្របខ័ណ្ឌនៃផែនការសកម្មភាពរួមសម្រាប់ដំណាក់កាលទី ៣ (CAP3 Framework),*** រួមមាន ៥ ផ្នែក, ២១ គោលបំណង និង ៦៥ ចង្កោមសកម្មភាព, ដែលត្រូវដាក់ជូនកិច្ចប្រជុំនេះពិនិត្យពិភាក្សា ហើយឈានទៅពិនិត្យសម្រេចយកធ្វើជាមូលដ្ឋានសម្រាប់ការរៀបចំផែនការសកម្មភាពរបស់ក្រសួង- ស្ថាប័ន និងរបស់គ្រប់អគ្គនាយកដ្ឋានក្រោមឱវាទក្រសួងសេដ្ឋ-កិច្ច និងហិរញ្ញវត្ថុ ឱ្យបានទាន់ពេលវេលា សម្រាប់ដាក់ឱ្យអនុវត្តនៅដើមឆ្នាំ ២០១៦ ខាងមុខ។

- **សម្តេចតេជោនាយករដ្ឋមន្ត្រី ជាទីគោរពដ៏ខ្ពង់ខ្ពស់,**
- **ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី, ភ្ញៀវជាតិ និងអន្តរជាតិ ជាទីមេត្រី!**

ផ្អែកលើបទពិសោធន៍នៃការអនុវត្តការងារកែទម្រង់ហិរញ្ញវត្ថុសាធារណៈក្នុងរយៈកាល ១០ ឆ្នាំកន្លងទៅនេះ, យើងក៏អាចយល់កាន់តែច្បាស់ផងដែរ អំពីចម្ងាយផ្លូវដែលយើងត្រូវបន្តធ្វើដំណើរ និងអំពីបញ្ហាប្រឈមដែលយើងត្រូវបន្តជួបប្រទះទៅមុខទៀត។ ជាការដកស្រង់បទពិសោធន៍, ខ្ញុំគិតថា បណ្តាចំណុចខ្លាំងដែលនាំឱ្យយើងសម្រេចបានជោគជ័យក្នុងពេលកន្លងមកនោះ គឺ: (១)- ចក្ខុវិស័យត្រឹមត្រូវ, (២)- ឆន្ទៈនយោបាយមុតស្រួចឥតរា-ថយ, (៣)- ការដឹកនាំឈ្លាសវៃ រស់រវើក និងបុរេសកម្ម, (៤)- ការចូលរួមយ៉ាងសកម្មពីគ្រប់ក្រសួង- ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ, (៥)- ការចូលរួមឧបត្ថម្ភគាំទ្រយ៉ាងពេញទំហឹងពីសំណាក់ដៃគូអភិវឌ្ឍន៍ ដោយគោរព ***«ភាពជា-ម្ចាស់»*** របស់រាជរដ្ឋាភិបាល និងដោយសម្របសម្រួលគ្នាបានយ៉ាងល្អប្រសើរតាមរយៈ ***«អភិក្រមគ្របដណ្តប់លើវិស័យទាំងមូល»*** និង (៦)- យន្តការគ្រប់គ្រង តាមដាន ត្រួតពិនិត្យ ប្រកបដោយស័ក្តិសិទ្ធភាព និងប្រសិទ្ធភាព។ ដូច្នេះ, ក្នុងឱកាសដ៏កម្រ និងវិសេសវិសាលនេះ, ក្នុងនាម **គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ** ខ្ញុំសូមអនុញ្ញាតសំដែងនូវការគោរព ដឹងគុណដ៏ជ្រាលជ្រៅបំផុត ជូនចំពោះ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដែលជានិច្ចកាលសម្តេចតែងបានផ្តល់នូវចក្ខុវិស័យដឹកនាំដ៏ភ្លឺស្វាង, ឈ្លាសវៃ, ប្រកបដោយគតិបណ្ឌិត និងផ្តល់នូវការគាំទ្រយ៉ាងពេញទំហឹង, ជាប់ជាប្រចាំ, ដល់កិច្ចការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនេះ ហើយអ្វីដែលរឹតតែជាពិសេសទៅទៀតនោះ គឺសម្តេចបានផ្តល់នូវគំរូវីរភាពក្នុងការគោរពវិន័យថវិកាដ៏ហ្មឹងម៉ាត់ ក្នុងឋានៈជា **«អគ្គមេបញ្ជាការតែមួយ»** នៅក្នុងការដឹកនាំការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ ទន្ទឹមនឹងនេះ ខ្ញុំក៏សូមសំដែងនូវការគោរពដឹងគុណដ៏ជ្រាលជ្រៅផងដែរ ជូន **ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ឧបនាយករដ្ឋមន្ត្រីប្រចាំការ គាត ឈន់** ចំពោះការដឹកនាំ និងការជំរុញលើកទឹកចិត្តជាប្រចាំរបស់ឯកឧត្តម ដល់កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, តាំងពីពេលដែលឯកឧត្តមនៅបំពេញមុខងារជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងនីតិកាលមុនៗ, រហូតមកដល់នីតិកាលទី ៥ នេះ, ដែលក្នុងឋានៈជាឧបនាយករដ្ឋមន្ត្រីប្រចាំការ, ឯកឧត្តមនៅតែបន្តជួយដឹកនាំ និងផ្តល់ការណែនាំតម្រង់ទិសដល់ការងារកែ-

ទម្រង់ការគ្រប់គ្រង់ហិរញ្ញវត្ថុសាធារណៈនេះ ក្នុងនាមជាប្រធាននៃ **គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។** ខ្ញុំក៏សូមថ្លែងអំណរគុណដ៏ស្មោះផងដែរ ជូនចំពោះមន្ត្រីគ្រប់ជាន់ថ្នាក់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរបស់ក្រសួង-ស្ថាប័នពាក់ព័ន្ធ ព្រមទាំងដៃគូអភិវឌ្ឍន៍ទាំងអស់ ដែលបានចូលរួមចំណែក និងផ្តល់ការគាំទ្រយ៉ាងសកម្ម ក្នុងស្មារតីលើកស្ទួយភាពជាម្ចាស់របស់កម្ពុជា និងក្នុងស្មារតីនៃការទទួលខុសត្រូវខ្ពស់ ដែលធ្វើឱ្យកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់យើងសម្រេចបានជោគជ័យគួរជាទីលើកទឹកចិត្ត ពីដំណាក់-កាលមួយទៅកាន់ដំណាក់កាលមួយទៀត។

ខ្ញុំសង្ឃឹមថា នៅក្នុងកិច្ចប្រជុំត្រួតពិនិត្យរយៈពេល ២ ថ្ងៃពេញខាងមុខនេះ យើងនឹងមានឱកាស និងពេល-វេលាគ្រប់គ្រាន់ សម្រាប់ការពិនិត្យ, ពិភាក្សា, មិនត្រឹមតែទៅលើវឌ្ឍនភាព និងបញ្ហាប្រឈមសម្រាប់ឆ្នាំ ២០១៤ កន្លងទៅប៉ុណ្ណោះទេ, ប៉ុន្តែ ផ្អែកលើបទពិសោធន៍ និងមេរៀនទាំងឡាយដែលទទួលបានការពិភាក្សានេះ, ពិសេសពី **«របាយការណ៍បឋមនៃការវាយតម្លៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ»** រៀបចំដោយ **អគ្គលេខាធិការដ្ឋាននៃគណកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**, យើងថែមទាំងអាចកំណត់បាននូវចំណុចខ្លាំង, ចំណុចខ្សោយ និងកង្វះខាតនានា សម្រាប់ជាមូលដ្ឋាននៃការបន្តជំរុញការអនុវត្តបពាប់ដំណាក់កាលទី ២, ក៏ដូចជាសម្រាប់ការរៀបចំផែនការសកម្មភាពដំណាក់កាល ៣ ដែលត្រូវបានគ្រោងនឹងដាក់ឱ្យអនុវត្តចាប់ពីឆ្នាំ ២០១៦ តទៅ។ ក្នុងស្មារតីនេះ ខ្ញុំសូមលើកទឹកចិត្តឱ្យមានការពិភាក្សាផ្លាស់ប្តូរគំនិត និងមតិ យោបល់ឱ្យបានផុស-ផុល, ជាពិសេស នៅក្នុងក្រុមពិភាក្សា ដែលមានពេលមួយព្រឹកពេញ, ដើម្បីបានជាធាតុចូលល្អៗសម្រាប់ការបន្តកែលម្អឯកសាររបស់យើង ឱ្យបានកាន់តែសុក្រឹត្យថែមទៀត, សំខាន់គឺ **«របាយការណ៍បឋមនៃការវាយតម្លៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ»** និង **«ក្របខ័ណ្ឌនៃផែនការសកម្មភាពរួមដំណាក់កាលទី ៣»** ដែលយើងត្រូវបន្តកែលម្អរហូតដល់ចុងឆ្នាំ ២០១៥ នេះ។

មុននឹងបពាប់, ក្នុងនាមគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, ខ្ញុំសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុត, ជាថ្មីម្តងទៀត, ជូនចំពោះ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដែលសម្តេចបានចំណាយពេលវេលាដ៏មមាញឹក និងមានតម្លៃបំផុតរបស់សម្តេច ដើម្បីផ្តល់ជាកិត្តិយសដល់កិច្ចប្រជុំត្រួតពិនិត្យប្រចាំឆ្នាំនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នាពេលនេះ ។ វត្តមានដ៏ខ្ពង់ខ្ពស់នេះ បង្ហាញឱ្យឃើញពីការយកចិត្តទុកដាក់ និងការផ្តល់សារៈសំខាន់ខ្ពស់របស់រាជរដ្ឋាភិបាល ចំពោះកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ហើយអង្គពិធីទាំងមូលសង្ឃឹមថានឹងទទួលបាននូវអនុសាសន៍ និងការណែនាំដ៏ខ្ពង់ខ្ពស់របស់សម្តេចតេជោនាយករដមន្ត្រី ដើម្បីបន្តជំរុញការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឱ្យសម្រេចបានជោគជ័យតាមការគ្រោងទុក, ជាពិសេសការបន្តជំរុញការអនុវត្តបពាប់ដណាក់កាលទី ២ នៅដំណាច់ឆ្នាំ ២០១៥ នេះ និងការឈានទៅចាប់ផ្តើមដំណាក់កាលទី ៣ នៅដើមឆ្នាំ ២០១៦ ខាងមុខ។

ជាថ្មីម្តងទៀតដែរ, ខ្ញុំសូមថែងអំណរគុណយ៉ាងជ្រាលជ្រៅ និងសូមកោតសសើរដោយស្មោះ ចំពោះការ-ខិតខំប្រឹងប្រែងយ៉ាងសកម្ម និងការពុះពារគ្រប់ឧបសគ្គរបស់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការទាំងអស់ នៃគ្រប់ក្រសួង-

ស្ថាប័នពាក់ព័ន្ធ កដូចជាមន្ត្រីគ្រប់ជាន់ថ្នាក់នៃអគ្គលេខាធិការដ្ឋាន, អគ្គនាយកដ្ឋាន, គណៈកម្មាការ និងក្រុមការងារទាំងអស់ក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រមទាំងដៃគូអភិវឌ្ឍន៍ទាំងអស់ ដែលបានរួមចំណែកអនុវត្ត និងបានផ្តល់កិច្ចសហការ និងការគាំទ្រដ៏មានតម្លៃ ដល់ការអនុវត្តកម្មវិធីកំណែទម្រង់របស់យើង តាំងពីដើមទីរហូតមកដល់បច្ចុប្បន្ននេះ។ ខ្ញុំសង្ឃឹមថា សារតីនៃភាពជាម្ចាស់, ការចូលរួមដោយបុរេសកម្ម, កិច្ចសហប្រតិបត្តិការ និងការគាំទ្រនេះ ច្បាស់ជានឹងបន្តរីកដុះដាលកាន់តែធំធាត់ឡើងថែមទៀត ទាំងនៅក្នុងដំណាក់កាលនេះ និងនៅក្នុងដំណាក់កាលបន្តបន្ទាប់ទៅមុខទៀត។

ជាទីបញ្ចប់, ខ្ញុំសូមគោរពប្រសិទ្ធពរជ័យជូន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា,** ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី, ភ្ញៀវជាតិ និងភ្ញៀវអន្តរជាតិទាំងអស់ សូមបានប្រកបដោយសុខភាពល្អ, កម្លាំងពលមាំមួន និងសម្រេចបានជោគជ័យដ៏ត្រចះត្រចង់ក្នុងគ្រប់ភារកិច្ច ដើម្បីបុព្វហេតុជាតិ, មាតុភូមិ និងការអភិវឌ្ឍ។

***ខ្ញុំសូមអរគុណចំពោះការយកចិត្តទុកដាក់!***